# សារៈសំខាន់នៃវិមជ្ឈការ

Eddie Dorotan, MD, MPA

វគ្គបណ្តុះបណ្តាលលើកទី២ស្តីអំពីការទទួលខុសត្រូវសង្គម

ទីក្រុងភ្នំពេញ កម្ពុជា

១៨ វិច្ឆិកា ២០០៨

# តើអ្វីទៅជាវិមជ្ឈការ

- គឺជាការផ្ទេរអំណាចគ្រប់គ្រង និងការទទួលខុសត្រូវ សម្រាប់មុខងារសាធារណៈពីរដ្ឋបាលថ្នាក់កណ្ដាលទៅឱ្យ ថ្នាក់ក្រោម  ឬ រដ្ឋបាលឯករាជ្យដែលមានកម្រិតច្បាស់លាស់ អង្គការ  និង/ឬ វិស័យឯកជនណាមួយ

# ប្រភេទផ្សេងៗនៃវិមជ្ឈការ

- ផ្នែកនយោបាយ
- ផ្នែករដ្ឋបាល
- ផ្នែកសារពើពន្ធ
- ផ្នែកទីផ្សារ

# វិមជ្ឈការផ្នែកនយោបាយ

- ផ្តល់ឱ្យប្រជាពលរដ្ឋ ឬអ្នកតំណាងដែលបានជ្រើសរើសនូវ**អំណាចបន្ថែម**ក្នុងការធ្វើសេចក្តីសម្រេចលើកិច្ចការសាធារណៈ
- ផ្តល់ឱ្យប្រជាពលរដ្ឋ ឬ អ្នកតំណាងដែលបានជ្រើសរើសនូវ**ឥទ្ធិពលបន្ថែម**ក្នុងការបង្កើត និងការអនុវត្តគោលនយោបាយផ្សេងៗ
- ធ្វើឱ្យប្រជាពលរដ្ឋ **យល់ដឹងប្រសើរជាងមុន ពី**អ្នកតំណាងនយោបាយរបស់ខ្លួន ហើយធ្វើឱ្យមន្ត្រីដែលបានជ្រើសរើសនោះយល់ដឹងបានប្រសើរជាងមុនអំពីតម្រូវការ និងការចង់បានរបស់ ប្រជាពលរដ្ឋ
- តម្រូវឱ្យមានកំណែទម្រង់ធម្មនុញ្ញ ឬ **កំណែទម្រង់ច្បាប់** ការរីកចម្រើននៃ **គណបក្ស**នយោបាយបែបពហុបក្សការពង្រឹង**ច្បាប់** ការបង្កើត**ស្ថាប័ននយោបាយតាមមូលដ្ឋាន** និងជំរុញឱ្យមាន**ក្រុម**ដែលចាប់អារម្មណ៏លើវិស័យសាធារណៈប្រកបដោយប្រសិទ្ធភាព

# វិមជ្ឈការផ្នែករដ្ឋបាល

- ស្វែងរកការបែងចែកសារជាថ្មីនៃ **អំណាចគ្រប់គ្រង** **ការទទួលខុសត្រូវ** និង **ធនធានហិរញ្ញវត្ថុ**សម្រាប់ផ្តល់នូវសេវាសាធារណៈក្នុងចំណោមរដ្ឋបាលថ្នាក់ខុសៗគ្នា
- ការផ្ទេរការទទួលខុសត្រូវសម្រាប់**ការរៀបចំផែនការ** **ការធ្វើហិរញ្ញប្បទាននិងការគ្រប់គ្រង**នៃប្រតិបត្តិសាធារណៈ**មួយចំនួន**ពីរដ្ឋបាលថ្នាក់កណ្តាល និងភ្នាក់ងារមួយចំនួនទៅកាន់ស្ថាប័នតាមមូលដ្ឋាន ស្ថាប័នក្រោមបង្គាប់នានា ឬ ថ្នាក់មូលដ្ឋាននានា អាជ្ញាធរសាធារណៈពាក់កណ្តាលស្វ័យ័ត ឬសាជីវកម្មនានា ឬអាជ្ញាធរតាមតំបន់ ឬតាមមុខងារ ។
- ប្រភេទទាំង៣ មាន : **វិសហមជ្ឈការ ការផ្តល់សិទ្ធិអំណាច ការផ្ទេរសិទ្ធិអំណាច**

# វិសហមជ្ឈការ

- ត្រូវបានគេចាត់ទុកជាទម្រង់ដែលខ្សោយបំផុតនៃវិមជ្ឈការ ហើយវាត្រូវបានគេប្រើនៅក្នុងរដ្ឋសហព័ន្ធមួយចំនួន
- **ផ្ទេរការបែងចែកសារជាថ្មីនូវអំណាចក្នុងការធ្វើការសម្រេចចិត្ត និងការទទួលខុសត្រូវលើផ្នែកហិរញ្ញវត្ថុ និងការគ្រប់គ្រង ក្នុងចំណោមលំដាប់ថ្នាក់ផ្សេងៗ** នៃរដ្ឋបាលថ្នាក់ ***កណ្តាល***
- អាចផ្លាស់ប្តូរបានត្រឹមតែការទទួលខុសត្រូវពីមន្ត្រីរដ្ឋបាលថ្នាក់កណ្តាលប៉ុណ្ណោះនៅក្នុងរាជធានីទៅកាន់អ្នកដែលធ្វើការនៅតាមតំបន់ តាមខេត្ត ឬ តាមស្រុក ឬ វាអាចបង្កើតឱ្យមានរដ្ឋបាលតាមមូលដ្ឋាន ឬសមត្ថភាពរដ្ឋបាលមូលដ្ឋានស្ថិតក្រោមការត្រួតពិនិត្យនៃស្រសួងរដ្ឋាភិបាលថ្នាក់កណ្តាល

# ការផ្តល់សិទ្ធិអំណាច

- វាជាទម្រង់បន្ថែមនៃវិមជ្ឈការ
- រដ្ឋបាលថ្នាក់កណ្តាលផ្ទេរការទទួលខុសត្រូវសម្រាប់ការធ្វើការសម្រេចចិត្ត និងរដ្ឋបាលមុខងារសាធារណៈទៅឱ្យបណ្តាអង្គការពាក់កណ្តាលស្វ័យ័ត **ដែលមិនគ្រប់គ្រងទាំងស្រុង**ដោយរដ្ឋបាលថ្នាក់កណ្តាល **ប៉ុន្តែជាអ្នកទទួលខុសត្រូវចុងក្រោយ**
- រដ្ឋបាលបែងចែកការទទួលខុសត្រូវ នៅពេលដែលគេ**បង្កើតសហគ្រាសសាធារណៈ សាជីវកម្ម អាជ្ញាធរលំនៅស្ថាន អាជ្ញាធរដឹកជញ្ជូន សេវាកម្មពិសេសតាមស្រុក សាលារៀនពាក់កណ្តាលស្វ័យ័តតាមស្រុក សាជីវកម្មអភិវឌ្ឍតាមតំបន់ ឬស្ថាប័នអភិវឌ្ឍគម្រោងពិសេសៗ** ។ ជាធម្មតាអង្គការទាំងនេះមានសេរីភាពយ៉ាងច្រើនក្នុងការធ្វើការសម្រេចចិត្ត ។
- ពួកគេប្រហែលជាអាចគេចផុតពីកាតព្វកិច្ចដែលបុគ្គលិកបម្រើសេវាកម្មស៊ីវិលទៀងទាត់ទូទៅត្រូវទទួលខុសត្រូវ ហើយប្រហែលជាអាចទារថ្លៃ ពីអ្នកប្រើប្រាស់សេវាកម្មដោយផ្ទាល់បាន ។

# ការផ្ទេរសិទ្ធិអំណាច

- ផ្ទេរអំណាចក្នុងការធ្វើសេចក្តីសម្រេច ហិរញ្ញវត្ថុ និងការងារគ្រប់គ្រងទៅឱ្យស្ថាប័នស្វ័យ័តជាក់លាក់នានានៃរដ្ឋបាលមូលដ្ឋាន**ដែលមានគោលជំហររួម។**
- ជាធម្មតាគឺផ្ទេរការទទួលខុសត្រូវសម្រាប់សេវាកម្មទៅឱ្យ**ថ្នាក់ក្រុងដែលជ្រើសរើសអភិបាលក្រុង និងក្រុមប្រឹក្សាដោយខ្លួនគេផ្ទាល់ បង្កើនប្រាក់ចំណូលរបស់គេផ្ទាល់ ហើយមានអាជ្ញាធរឯករាជ្យដើម្បីធ្វើការសម្រេចលើការវិនិយោគនានាបាន**
- រដ្ឋបាលថ្នាក់មូលដ្ឋានមានព្រំដែនភូមិសាស្ត្រដែលត្រូវបានទទួលស្គាល់យ៉ាងច្បាស់លាស់ និងដោយស្របច្បាប់ដែលគេអាចប្រើប្រាស់អំណាចបាន និង ដែនកំណត់ដែលគេអាចអនុវត្តមុខងារសាធារណៈបាន។
- នេះគឺជាប្រភេទនៃវិមជ្ឈការផ្នែករដ្ឋបាលដែល**ស្ថិតនៅក្រោមវិមជ្ឈការផ្នែកនយោបាយភាគច្រើន។**

# វិមជ្ឈការផ្នែកសារពើពន្ធ

- ប្រសិនបើរដ្ឋបាលមូលដ្ឋាន និងអង្គការឯកជននានាត្រូវបន្តអនុវត្តមុខងារវិមជ្ឈការឱ្យមានប្រសិទ្ធភាពនោះ ពួកគេត្រូវតែមាន**កម្រិតចំណូលគ្រប់គ្រាន់** អាចជាចំណូលដែលទទួលបានពីមូលដ្ឋាន ឬ ចំណូលដែលទទួលបានពីការផ្ទេរពីរដ្ឋបាលថ្នាក់កណ្តាល ព្រមទាំង**អំណាចក្នុងការធ្វើការសម្រេចចិត្តទៅលើការចំណាយផ្សេងៗ។**
- នៅក្នុងប្រទេសកំពុងអភិវឌ្ឍជាច្រើនរដ្ឋបាលថ្នាក់មូលដ្ឋាន ឬ ស្ថាប័នរដ្ឋបាលនានាមានអំណាចស្របច្បាប់ក្នុងការកំណត់ពន្ធ ប៉ុន្តែមូលដ្ឋាននៃពន្ធគឺមិនមានភាពខ្លាំងហើយការពឹងផ្អែកទៅលើឧបត្ថម្ភធនរបស់រដ្ឋបាលថ្នាក់កណ្តាលមានការពិបាកដែលធ្វើឱ្យគ្មានការអនុវត្តនូវអំណាចទាំងនោះ។

# វិមជ្ឈការផ្នែកសារពើពន្ធ

**ទម្រង់នៃ** វិមជ្ឈការសារពើពន្ធ:

- **ស្វ័យហិរញ្ញប្បទាន**ឬ ភាពធូរស្រាលនៃការចំណាយតាមរយៈការគិតថ្លៃពីអ្នកប្រើប្រាស់
- **សហហិរញ្ញប្បទាន**ឬ ការរៀបចំសាជាថ្មីនៃសហផលិតកម្មតាមរយៈដែលអ្នកប្រើប្រាស់ចូលរួមនៅក្នុងការផ្តល់នូវសេវា និងហេដ្ឋារចនាសម្ព័ន្ធតាមរយៈការចែកចាយនូវរូបិយវត្ថុ ឬ កម្លាំងពលកម្ម
- ការទទួលបានបន្ថែមនូវ **ប្រាក់ចំណូលតាមមូលដ្ឋាន**តាមរយៈពន្ធលើព្រទ្យសម្បត្តិ ឬ ការលក់ ឬ ការគិតថ្លៃដោយប្រយោលផ្សេងៗ
- **ការផ្ទេរ**អន្តររដ្ឋាភិបាលដែលផ្លាស់ប្តូរប្រាក់ចំណូលពីពន្ធដែលប្រមូលបានដោយរដ្ឋបាលថ្នាក់កណ្តាល ទៅឱ្យរដ្ឋអំណាចមូលដ្ឋានដើម្បីប្រើប្រាស់ក្នុងគោលបំណងជាក់លាក់ ឬ ជាទូទៅនានា
- ការផ្តល់សិទ្ធិក្នុង**ការខ្ចី**ពីក្រុង ហើយនិងការប្រមូលទាំងធនធានរបស់ជាតិ និងធនធានរដ្ឋបាលមូលដ្ឋាន តាមរយៈការធានាប្រាក់កម្ចី ។

# វិមជ្ឈការផ្នែកទីផ្សារ

- ទម្រង់ពេញលេញភាគច្រើននៃវិមជ្ឈការពីទស្សនវិស័យរបស់រដ្ឋាភិបាលគឺជា **ឯកជនភាវូបនីយកម្ម និងការកាត់បន្ថយការត្រួតត្រារបស់រដ្ឋាភិបាល** ព្រោះគេផ្លាស់ប្តូរការទទួលខុសត្រូវចំពោះមុខងារ **ពីវិស័យសាធារណៈទៅជាវិស័យឯកជន**
- ការធ្វើឯកជនភាវូបនីយកម្ម និងការកាត់បន្ថយការត្រួតត្រារបស់រដ្ឋគឺជាទូទៅគេធ្វើស្របគ្នាទៅនឹងសេរីភាវូបនីយកម្មសេដ្ឋកិច្ច និងគោលនយោបាយអភិវឌ្ឍទីផ្សារ
- គេអនុញ្ញាតឱ្យកិច្ចការដែលមានការទទួលខុសត្រូវជាចំបង ឬ ដោយផ្ទាល់មុខដោយរដ្ឋាភិបាល អាចអនុវត្តបានដោយអ្នកជំនួញនានា ក្រុមសហគមន៍ សហករ សមាគមស្ម័គ្រចិត្តឯកជន និងបណ្តាអង្គការក្រៅរដ្ឋាភិបាលដទៃៗទៀត ។

# ឯកជនភាវូបនីយកម្ម

- អាចរៀបរាប់ចាប់ពី ការផ្តល់ទំនិញ និងសេវាកម្ម ទៅឱ្យប្រតិបត្តិការសេរីនៃទីផ្សារ រហូតដល់ " ភាពជាដៃគូ នៃសាធារណៈ និងឯកជន " ដែលរដ្ឋាភិបាល និងវិស័យឯកជនធ្វើសហប្រតិបត្តិការជាមួយគ្នាក្នុងការផ្តល់ឱ្យនូវសេវាកម្ម ឬ ហេដ្ឋារចនាសម្ព័ន្ធ ។

# ឯកជនភាវូបនីយកម្ម

ឯកជនភាវូបនីយកម្មអាចរួមមានៈ

- អនុញ្ញាតឱ្យសហគ្រាសឯកជនដំណើរការមុខងារដែលពីមុនកាន់កាប់ផ្តាច់មុខដោយរដ្ឋាភិបាល
- ការប្តូរពីការផ្តល់ជូន ឬការគ្រប់គ្រងសេវាសាធារណៈ ដោយរដ្ឋាភិបាល ទៅឱ្យសហគ្រាសពាណិជ្ជកម្មនានា
- ផ្តល់ហិរញ្ញប្បទានទៅឱ្យកម្មវិធីផ្នែកសាធារណៈ តាមរយៈទីផ្សារមូលធន (ជាមួយនឹងបទបញ្ជា ឬវិធានការដែលគ្រប់គ្រាន់ដើម្បីការពារស្ថានភាពដែលរដ្ឋបាលថ្នាក់កណ្តាលប្រឈមមុខនឹងកម្មវិធីទាំងនេះ) និងអនុញ្ញាតឱ្យអង្គការឯកជនចូលរួម
- ផ្ទេរការទទួលខុសត្រូវសម្រាប់ការផ្តល់សេវា ពីវិស័យសាធារណៈទៅឱ្យវិស័យឯកជនតាមរយៈលក់ដូរ ។

# ការផ្តល់សិទ្ធិអំណាច

- វាកាត់បន្ថយការរឹតបន្តឹងនៃច្បាប់ដោយអនុញ្ញាតឱ្យមានការចូលរួមពីវិស័យឯកជន នៅក្នុងការផ្តល់សេវាសាធារណៈ ឬ អនុញ្ញាតឱ្យមានការប្រកួតប្រជែង ក្នុងចំណោម អ្នកផ្តល់សេវាឯកជន ដែលកាលពីពេលមុនធ្លាប់តែផ្តល់ដោយរដ្ឋាភិបាល ឬ ដោយក្រុមហ៊ុនផ្តាច់មុខ
- ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ឯកជនភាវូបនីយកម្ម និងការកាត់បន្ថយការគ្រប់គ្រង ដោយរដ្ឋ បានក្លាយទៅជាជម្រើសដែលគួឱ្យទាក់ទាញសម្រាប់រដ្ឋាភិបាលក្នុងការ អភិវឌ្ឍប្រទេស ។
- រដ្ឋបាលមូលដ្ឋានកំពុងធ្វើឯកជនភាវូបនីយកម្មដោយដកចេញនូវបញ្ញត្តិស្តីពីសេវា ឬ កិច្ចការរដ្ឋបាល ។

# ការជ្រើសរើសយកទម្រង់វិមជ្ឈការដែលសមស្របបំផុត (ហេតុអ្វីត្រូវជ្រើសរើសវិមជ្ឈការ?)

- **ពង្រីកការចូលរួម**ក្នុងវិស័យនយោបាយ  សេដ្ឋកិច្ច និងសកម្មភាពសង្គមនានាក្នុងការអភិវឌ្ឍរបស់ប្រទេសជាតិ ។
- ជួយ**បន្ធូរបន្ថយដល់ភាពតឹងតែងក្នុងការធ្វើសេចក្ដីសម្រេច**
- **ជួយកាត់បន្ថយនីតិវិធីការិយាធិបតេយ្យ**
- **បង្កើននូវការគិតរបស់មន្ត្រីរដ្ឋាភិបាល**ចំពោះលក្ខខណ្ឌ និងតម្រូវការតាមមូលដ្ឋាន ។
- **សេវាកម្មចូលដល់តំបន់តាមមូលដ្ឋានច្រើនជាងមុន**

# ហេតុអ្វីត្រូវជ្រើសរើសវិមជ្ឈការ?

- អនុញ្ញាត **ឱ្យមានតំណាងផ្នែកនយោបាយកាន់តែច្រើនជាងមុន** សម្រាប់ការផ្លាស់ប្តូរផ្នែកនយោបាយ ក្រុមជនជាតិ សាសនា និងក្រុមវប្បធម៌ក្នុងការធ្វើសេចក្តីសម្រេច
- ជួយបន្ធូរបន្ថយដល់អ្នកគ្រប់គ្រងថ្នាក់កំពូលនានានៅក្នុងក្រសួងរបស់រដ្ឋាភិបាលលើកិច្ចការ "ដដែលៗ" ទៅ **គិតគូរលើគោលនយោបាយវិញ**។
- បង្កើតនូវ**ចំណុចផ្តោតនៃភូមិសាស្ត្រមួយ**នៅតាមថ្នាក់មូលដ្ឋានសម្រាប់សម្របសម្រួលដល់កម្មវិធីថ្នាក់ជាតិ ថ្នាក់រដ្ឋ ថ្នាក់ខេត្ត ថ្នាក់ស្រុក និងថ្នាក់មូលដ្ឋានឱ្យកាន់តែមានប្រសិទ្ធភាព និងអាចផ្តល់នូវឱកាសប្រសើរជាងមុនសម្រាប់ការចូលរួមពីប្រជាជននៅក្នុងការធ្វើសេចក្តីសម្រេច។
- វិមជ្ឈការអាចនាំឱ្យមាន**កម្មវិធីដែលមានលក្ខណៈ បង្កើតថ្មី លក្ខណៈច្នៃប្រឌិត និងលក្ខណៈឆ្លើយតបបន្ថែមទៀត** ដោយអនុញ្ញាតឱ្យមាន "ការពិសោធនៅតាម" មូលដ្ឋាន។
- វាក៏អាចបង្កើននូវ**ស្ថេរភាពនយោបាយ និងការបង្រួបបង្រួមជាតិ**ដោយអនុញ្ញាតឱ្យប្រជាពលរដ្ឋទទួលបាននូវកម្មវិធីសាធារណៈក្នុងការគ្រប់គ្រងបានប្រសើរជាងមុននៅតាមថ្នាក់មូលដ្ឋាន។

# គុណវិបត្តិធំៗ

- អាចមិនមានប្រសិទ្ធភាព ជាពិសេសចំពោះសេវាកម្មដដែលៗតាមមូលដ្ឋាន ។
- វាអាចបណ្តាលឱ្យមាន**ការធ្លាក់ចុះនៃមាត្រដ្ឋានសេដ្ឋកិច្ច** និងការគ្រប់គ្រងលើធនធានហិរញ្ញវត្ថុដែលខ្វះខាតពីសំណាក់រដ្ឋបាលថ្នាក់កណ្តាល ។
- ផ្នែករដ្ឋបាល ឬសមត្ថភាពបច្ចេកទេសដែលខ្សោយនៅតាមថ្នាក់មូលដ្ឋានអាចប៉ះពាល់ដល់**សេវាដែលកំពុងត្រូវបានគេចែកចាយកាន់តែលែងមានប្រសិទ្ធភាព** នៅក្នុងតំបន់មួយចំនួននៅក្នុងប្រទេស ។
- ការទទួលខុសត្រូវផ្នែករដ្ឋបាលអាចត្រូវបានផ្ទេរទៅកាន់ថ្នាក់មូលដ្ឋានដោយមិនមានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ **ហើយធ្វើឱ្យការបែងចែក និងការផ្តល់សេវាកម្មដែលមានសមភាពកាន់តែពិបាកឡើង ។**
- វិមជ្ឈការពេលខ្លះ **ធ្វើឱ្យការសម្របសម្រួលគោលនយោបាយថ្នាក់ជាតិកាន់តែស្មុគស្មាញថែមទៀត ហើយអាចឱ្យអ្នកមានអំណាចនៅមូលដ្ឋានចាប់យកនូវអំណាចទាំងនោះ ។ ជាមួយគ្នានេះផងដែរ** ធ្វើឱ្យមានភាពដែលមិនជឿជាក់រវាងវិស័យ សាធារណៈ និងឯកជនដែលបណ្តាលឱ្យការសម្របសម្រួលនៅថ្នាក់មូលដ្ឋានកាន់តែខ្សោយទៅៗ ។

# អ្វីដែលត្រូវធ្វើ

- អ្នករៀបចំផែនការគម្រោង និងកម្មវិធីត្រូវតែមានសមត្ថភាពអាចវាយតម្លៃទៅលើ **ភាពខ្លាំង និងភាពខ្សោយ**នៃអង្គការទាំងផ្នែកឯកជន និងផ្នែកសាធារណៈក្នុងការប្រតិបត្តិមុខងារប្រភេទផ្សេងៗគ្នា។
- នៅមុនពេលបង្កើតគម្រោងលម្អិតសម្រាប់វិមជ្ឈការ គេត្រូវតែ**វាយតម្លៃទៅលើកម្រិតនៃការរៀបចំដែលទាបបំផុតនៃរដ្ឋបាលដែលមានមុខងារអាចត្រូវបានបំពេញដោយមានប្រសិទ្ធភាព និង**ទម្រង់ដែលសមស្របបំផុតនៃឯកជនភាវូបនីយកម្ម។

# អ្វីដែលត្រូវធ្វើ

- មជ្ឈការ និងវិមជ្ឈការគឺ **មិនមែនជាលក្ខខណ្ឌ "ដែលអាចជ្រើសរើសមួយហើយចោលមួយនោះទេ"** ។
- នៅក្នុងប្រទេសភាគច្រើន **តុល្យភាពនៃ**មជ្ឈការ និងវិមជ្ឈការ គឺមានសារៈសំខាន់ណាស់ក្នុងការអនុវត្តមុខងាររដ្ឋបាលឱ្យមានប្រសិទ្ធភាពនិងប្រសិទ្ធផល ។
- មិនមែនគ្រប់មុខងារទាំងអស់ គួរត្រូវធ្វើហិរញ្ញប្បទាននិងគ្រប់គ្រងតាមរបៀបផ្ទេរអំណាចនោះទេ ។

# អ្វីដែលត្រូវធ្វើ

- ទោះបីជារដ្ឋបាលថ្នាក់ជាតិផ្ទេរការទទួលខុសត្រូវក៏ដោយ ក៏គេតែងតែរក្សានូវ **គោលនយោបាយ និងតួនាទីគ្រប់គ្រងដែលសំខាន់ទុកនៅដែរ ។**
- គេត្រូវតែបង្កើត ឬ រក្សានូវ **"លក្ខខណ្ឌជាជំនួយ"** ដែលអនុញ្ញាតឱ្យស្ថាប័នរដ្ឋបាល ថ្នាក់មូលដ្ឋាន ឬ អង្គការក្រៅរដ្ឋាភិបាលឱ្យទទួលខុសត្រូវបន្ថែមទៀតដែរ ។
- បង្កើតនូវគោលនយោបាយ និងបទបញ្ញាថ្នាក់ជាតិដែលសមស្រប ហើយមានប្រសិទ្ធភាពសម្រាប់វិមជ្ឈការ និងពង្រឹងសមត្ថភាពស្ថាប័នតាមមូលដ្ឋានដើម្បីទទួលខុសត្រូវចំពោះមុខងារថ្មី ។
- ភាពជោគជ័យនៃវិមជ្ឈការជាញឹកញាប់តែងតែពឹងផ្អែកយ៉ាងខ្លាំងលើការបណ្តុះបណ្តាលមន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានអំពីរដ្ឋបាលបែបវិមជ្ឈការ ។
- **ជំនួយផ្នែកបច្ចេកទេស** ជារឿយៗតែងតែត្រូវការសម្រាប់រដ្ឋបាលថ្នាក់មូលដ្ឋានដូចជា សហគ្រាសឯកជន និងក្រុមមិនមែនរដ្ឋាភិបាលតាមមូលដ្ឋាននៅក្នុងការធ្វើគម្រោង ការធ្វើហិរញ្ញប្បទាននិងការគ្រប់គ្រងមុខងារវិមជ្ឈការផ្សេងៗ ។